របាយការណ៍ស្តីអំពី

ការចុះទៅចុះស្រាវជ្រាវរណ្តៅសាកសព និងសម្ភាសសាក្សីទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ

នៅស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួចខេត្តខេត្តកំពង់ស្ពឺ លើកទី៣

**ដោយៈ ជួង សុភារិទ្ធ**

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០០ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចាត់តាំងក្រុមដែនទីដែលរួមមានៈ

- លោក ស៊ិន ឃិន
- លោក ផេង ពង្សរ៉ាស៊ី
- លោក អ៊ុច សំអឿន
- លោក ជួង សុភារិទ្ធ

សហការីទាំងបួននាក់បានចុះទៅស្រុកឱរ៉ាល់ និងស្រុកភ្នំស្រួចដើម្បីស្រាវជ្រាវរកភស្តុតាង និងសាក្សីដែលបានដឹងឮទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ វេលាម៉ោង៧ៈ០០ក្រុមស្រាវជ្រាវយើងបានធ្វើដំណើដោយរថយន្តចេញពីក្រុងភ្នំពេញឆ្ពោះទៅសាលាខេត្តកំពង់ស្ពឺ ដើម្បីទំនាក់ទំនងការងារជាមួយលោកអភិបាលខេត្ត ។ ក្រុមយើងមកដល់សាលាខេត្តនៅវេលាម៉ោង៨ៈ២៥នាទីព្រឹក ។ ប៉ុន្តែដោយសារថ្ងៃដែលយើងចុះទៅត្រូវចំថ្ងៃទិវាកុមារអន្តរជាតិ និងជាដែលមន្ត្រីរាជការត្រូវឈប់សំរាកពីការងារផងនោះ ជាហេតុធ្វើឲ្យយើងមិនបានជួបទំនាក់ទំនងការងារជាមួយលោកអភិបាលខេត្តឡើយ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយក្រុមយើងបានបន្តដំណើរទៅមុខទៀតសំដៅទៅស្រុកឱរ៉ាល់តែម្តង ។ ការធ្វើដំណើរចេញពីសាលាខេត្តតាមផ្លូវជាតិលេខ៤ឆ្ពោះមកទិសខាងលិចចំងាយប្រហែល២គីឡូម៉ែត្រដល់ត្រង់ផ្លូវបំបែកច្បាមនបត់ទៅទិសខាងជើង ។ ចាប់ពីផ្លូវបំបែកច្បារមនទៅដល់ទំនប់អូរកំពិសមានចំងាយប្រហែលជា៥គីឡូមែត្រ ហើយយើងបត់ទើសលិចតាមផ្លូវលំខាងជើងខ្នងទំនប់អូរកំពិសឆ្ពោះទៅស្រុកឱរ៉ាល់ ។ យើងទៅដល់ស្រុកឱរ៉ាលនៅម៉ោង៩ៈ៤៥នាទីព្រឹក ។ ចាប់ពីសាលាខេត្តទៅដល់ស្រុកឱរ៉ាល់មានចំងាយជាង៥០គីឡូម៉ែត្រ ។

ពេលទៅដល់ស្រុកឱរ៉ាល់ភ្លាមយើងបានចូលទៅទំនាក់ទំនងការងារជាមួយលោកអភិបាលស្រុក ។ ប៉ុន្តែដោយថ្ងៃនោះត្រូវនឹងថ្ងៃដែលមន្ត្រីរាជការឈប់សំរាក យើងមិនបានជួបលោកអភិបាលស្រុកឡើយ ។ ទោះជាយ៉ាងនោះក្តីយើងបានបន្តដំណើរទៅមុខទៀតដោយឆ្លងកាត់ស្ទឹងមួយដែលមានស្ពានដ៏ចាស់ទ្រុតទ្រោម ។ ឆ្លងកាត់ស្ពាននោះបានបន្តិច យើងទៅដល់ការដ្ឋានសាងសង់ផ្លូវមួយកន្លែងដែលកំពង់ធ្វើការសាងសង់ស្ថិតនៅក្នុងភូមិទ្រនាប់ ឃុំសង្កែស្រទប ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ ស្ថានភាពផ្លូវមានការលំបាកខ្លាំណាស់ដោយសារលំដីស្អិត ហើយរអិលដែលអាចធ្វើឲ្យឡានធ្លាក់ផ្លូវបាន ។ ម្យ៉ាងទៀតផ្លូវខាងមុខក៏កាន់តែមានការលំបាក ព្រោះនៅតាមផ្លូវរលីករលាក់ និងមានជង្ហុក់ជ្រៅ ហើយស្ងាត់ពុំមានផ្ទះប្រជាជនរស់នៅទេ ជាហេតុធ្វើឲ្យការធ្វើដំណើចុះស្រាវជ្រាវរបស់យើងមិនអាចបន្តរទៅមុខទៀតដោយសារតែស្ថានភាពមិនអំណោយផលនេះ ។

ឆ្លៀតពេលនោះយើងបានសាកសួរពត៌មានពីនរគបាលស្រុកម្នាក់ឈ្មោះ អ៊ូ ម៉ុន នៅភូមិរស្មីសាមគ្គី ។ គាត់ជាអតីតទ័ពខ្មែរក្រហម ហើយគាត់បានរៀបរាប់ប្រាប់យើងឲ្យដឹងថាមន្ទីរ៩៩ ហៅកំពូល៩ ស្ថិតនៅក្នុងឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺដែលមានចំងាយ១២គីឡូម៉ែត្រពីភូមត្រាពាំងឃ្លា ។ នេះជាពត៌មានថ្មីមួយដែលយើងទទួលបាន ក្នុងការចុះស្រាវជ្រាវលើកទី៣ ។

ក្រោយពីយើងទទួលបានពត៌មានថាទីតាំងដែលយើងចុះទៅនៅស្រុកឱរ៉ាល់មិនអាចធ្វើដំណើរទៅបាន យើងក៏ត្រឡប់មកទីរួមខេត្តកំពង់ស្ពឺវិញ ហើយក៏បានបន្តដំណើរទៅស្រាវជ្រាវទីតាំងមួយកន្លែងទៀតស្ថិតក្នុងឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ នៅ



DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

វេលាម៉ោង៧ៈ០០យើងបានទៅដល់ឃុំដំបូករូង ហើយបានជួបសម្ភាសជាមួយលោកប្រធានភូមិឈ្មោះ មួង ឡាវ ។ ពត៌មានដែលយើងទទួលបានពីទីតាំងសម្លាប់ គឺមាននៅដុលអិល ត្រពាំងអំពិល និងស្វាយផ្អែម ។ ទាំងបីកន្លែងនេះជាទីតាំងដែលយើងមិនទាន់ចុះទៅដល់ដែលមានចំងាយជាង១០គីឡូម៉ែត្រពីសាលាឃុំដំបូករូង ប៉ុន្តែឥឡូវគ្មានប្រជាជនរស់នៅទេ ហើយមានសុទ្ធតែព្រៃ ។ ចំពោះទីតាំងសម្លាប់នៅដុកអិលពួកខ្មែរក្រហមយកប្រជាជនទៅសម្លាប់ក្នុងឆ្នាំ១៩៧៥ ។ នៅទីតាំងនេះប្រសិនណាគ្មានភ្លៀងគឺយើងអាចធ្វើដំណើរដោយរថយន្តទៅបាន ប៉ុន្តែមិនអាចទៅដល់ទីតាំងនោះផ្ទាល់បានទេ គឺយ៉ាងហោចណាស់ក៏ត្រូវដើរ ឬជិះទេះគោបន្តិចបន្តួចទៀតទើបទៅដល់ ហើយទីតាំងសម្លាប់នៅត្រពាំងអំពិលក៏ដូចគ្នាដែរ ។

ដោយឡែកមន្ទីរសន្តិសុខនៅស្វាយផ្អែមដែលកាលពីជំនាន់កម្ពុជាប្រជាធិបតេយ្យ ពួកខ្មែរក្រហមបាននាំយកប្រជាជនទៅដាក់ឃុំឃាំងបង្អត់អាហាររហូតទាល់តែស្លាប់ ហើយយកទៅកប់ចោលនៅក្បែរនោះតែម្តង ហើយអ្នកណាដែលត្រូវសម្លាប់ក៏សម្លាប់ចោលនៅទីនោះដែរ ។ នេះជាពត៌មានថ្មីៗដែលយើងទួលបានក្នុងការចុះស្រាវជ្រាវលើកទី៣ ។

ប៉ុន្តែកាលដែលយើងចុះទៅធ្វើការស្រាវជ្រាវលើកទី២យើងបានមកដល់សាលាឃុំដំបូករូង ហើយបានជួបមេឃុំ មួង ឡៅ ជីវពលឃុំ កង ខេម នគរបាលឃុំ និងប្រជាជនមួយចំនួន ។ ពត៌មានផ្សេងៗដែលទទួលបានពីលោកមេឃុំ ដោយចាក់កាសែតរក្សាទុកឯកសារដែលពត៌មាននោះមានដូចតទៅៈ

**-ទីតាំងប្រល័យពូជសាសន៍**ៈ កាប់សំលាប់ និងគុកសន្តិសុខសម័យ៣ឆ្នាំ ៨ខែ ២០ថ្ងៃ ។ លោក មួង ឡៅ បានប្រាប់អោយយើងដឹងថាសន្តិសុខគុកខ្មែរក្រហមឋិតនៅត្រពាំងស្វាយផ្អែមចំងាយពីសាលាឃុំ១០គមពីសាលាឃុំទីតាំងនេះបច្ចុប្បន្នគ្មានប្រជាជនរស់នៅទេ គឺមានសុទ្ធតែព្រៃ ហើយធ្វើដំណើរដោយរទេះគោ ឬដើរ ។ បើសិនទៅម៉ោង១១ៈ០០ព្រឹកម៉ោង៨ៈ០០ ឬ៥ៈ០០ល្ងាចទើបមកដល់សាលាឃុំវិញ ។

*ទីតាំងសម្លាប់មានច្រើនដូចជាៈ១-ដុកអិល ២ត្រពាំងសារាយ ៣-ត្រពាំងអំពិល ៤-តុងឡុង ឬព្រៃប្រម៉ង់ពង ៥-អូរផ្លាវ ឬអូរចោលជាល និង៦-ទួលជា ។*

ក្រោយពីបានដឹងពត៌មាននេះរួច យើងបានសួរអំពីរមធ្យោបាយដែលត្រូវធ្វើដំណើរទៅកាន់ទីតាំងសំលាប់ទាំងអស់នោះ ។ លោក មួង ឡៅ លោក កង ខេម ប្រជាជនគាត់បានប្រាប់យើងថា រដូវនេះធ្វើដំណើររទេះគោ គ្មានឡាន ម៉ូតូឌុបទេ ព្រោះផ្លូវទឹកសងខាងព្រៃសុទ្ធ និងគ្មានប្រជារាស្ត្ររស់នៅទីនោះទេ ។ ចំងាយដូនទៅ១២គម., ១០គម.ទីតាំងខ្លះពី៥ទៅ៦គម ហើយបើសិនទៅបានតែមួយទីតាំងទេ មិនអាចទៅបានទាំងអស់ទេ មូលហេតុចំងាយពីទីតាំងមួយទៅទីតាំងមួយទៀតឆ្ងាយពីគ្នា១០គម ឬ៦គម ។ បើយើងចង់ស្រាវជ្រាវអោយអស់ទីតាំងត្រូវប្រើពេលវេលា៥ថ្ងៃ ហើយត្រូវខ្ចប់បាយទឹកទៅជាមួយផង ។ រឿងសន្តិសុខមិនចោទទេ មីនក៏គ្មានដែរ ។

**-ការស្វាបស្ទង់ពត៌មានជនរងគ្រោះត្រូវពួកឃាតករសម្លាប់**

-ប្រភេទជនរងគ្រោះរួមមាន ៈ

-ពួកដែលចេញពីក្រុងឆ្នាំ១៩៧៥ ពួកនេះគឺទាហ៊ាន ប៉ូលិស គ្រូបង្រៀន សាស្ត្រាចារ្យ មន្ត្រីរដ្ឋការស៊ីវិល យុវជនយុវនារី កូនក្មេង ប្រពន្ធ ត្រូវខ្មែរក្រហមសំលាប់ទាំងអស់ ពួកវាស្តុបទុករយៈពេល៤-៥ថ្ងៃ រួចហើយបញ្ចេញម្តង១០-២០គ្រួសារ រួចវាយសម្លាប់នៅឆ្នាំ១៩៧៥, ១៩៧៦តែម្តង ។ នៅគ្រប់ទីតាំងអោយតែពួកចេញពីទីក្រុងឆ្នាំ១៩៧៥ ។

-ប្រភេទមួយទៀតទាហ៊ានៅបន្ទាយដោះកញ្ជរ ឋិតក្នុងស្រុកភ្នំស្រួច បន្ទាយនេះបែកក្រោយគេពួកវាចាប់ទាំងមន្ត្រីរដ្ឋការ គ្រូបង្រៀន ទាហ៊ាន ប្រពន្ធទាហ៊ាន ព្រះសង្ឃ សម្លាប់ដោយឡែក គ្មានទុកម្នាក់ឡើយសម្លាប់ប្រហែលជាង១០០០០នាក់សម្តីលោក មួង ឡៅ សាក្សីទី១ ។

-ប្រភេទជនរងគ្រោះម្យ៉ាងទៀត បញ្ចេញពីគុកសន្តិសុខទួលស្វាយផ្អែម ទៅសម្លាប់ទីតាំងក្បែរៗ គុកសម្លាប់មានរណ្តៅខ្លះ អត់រណ្តៅខ្លះ គឺសម្លាប់ចោលក្នុងព្រៃតែម្តង ។

-ចំពោះអដ្ឋិធាតុគ្មានសល់ទេ

-នៅឆ្នាំ១៩៧៨ ពួកខ្មែរក្រហមដាក់បញ្ជាអោយរាស្ត្រប្រមូលយកដុតធ្វើជី ដូច្នេះអដ្ឋិធាតុគ្មានសល់ទេ (នេះវាវៃចោលលើដីគ្មានរណ្តៅ) ។

-ប្រភេទជនរងគ្រោះម្យ៉ាងទៀតពួកកើតជំងឺឃ្លង់ ពួកនេះសម្លាប់ចុងក្រោយគេ ។ នៅឆ្នាំ១៩៧៩ អ្នកជីករកមាសលោក កង ខេម ដឹកផ្ទាល់ គាត់ថាសាច់នៅមិនរលាយអស់នៅឡើយ ។ ពួកឃ្លង់គេសម្លាប់ទាំងគ្រួសារៗ ក្មេង ចាស់ ប្រុស ស្រី រួចពួកវាបាចកំបោរពីលើរណ្តៅ ។ សម្លាប់នៅទីតាំងតុងឡុង ប្រហែលពី៥-៦រណ្តៅ ចំនួនអ្នកត្រូវសម្លាប់ប្រហែលជាង១០០គ្រួសារ ។

**-ចំនួនជនរងគ្រោះត្រូវស្លាប់ទាំង៦ទីតាំងស្ថិតនៅក្នុងឃុំដំបូករូង**

-តាមការប៉ាន់ស្មានរបស់សាក្សី មួង ឡៅ និងសាក្សី កង ខេម គឺនៅបន្ទាយដោះកញ្ជរមានចំនួនជាង១០,០០០នាក់ ហើយអ្នកចេញពីទីក្រុងបូករួមនឹងពួកមូលដ្ឋាន និងអ្នកជាប់គុកផងមានចំនួនជាង២០,០០០នាក់ សរុបចំនួនជាង៣០,០០០នាក់ ។

១- ប្រវត្តិសាក្សីទាំងពីរ **មួង ឡៅ** និង **កង ខេម**

- មួង ឡៅ សម័យសង្គមរាស្ត្រនិយមនៅទីនោះ សម័យលន់ណុលមកភ្នំពេញធ្វើទាហ៊ានសម័យប៉ុលពតពី១៩៧៥ដល់១៩៧៩មកនៅភូមិត្រពាំងត្រាច ឃុំដំបូករូង ពីឆ្នាំ១៩៧៩ធ្វើជាមេឃុំដំបូករូង ។ ដូច្នេះគាត់ឃើញដឹងព្យច្បាស់ព្រមទាំងស្គាល់អ្នកដៃដល់អ្នកសំលាប់ទៀតផង ។ សាក្សី មួង ឡៅ បានបញ្ជាក់ថាជនដៃដល់សម្លាប់ប្រជាជនរងគ្រោះគឺ១-ម៉ៅ ធុម នៅភូមិដំបូករូង ឃុំដំបូករូង និង២-មុី ឃួន នៅភូមិសំប៊ួរ ឃុំដំបូករូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

ជននេះនៅរស់ទាំងពីរនាក់ យើងមិនបានទៅជួបផ្ទាល់យកពត៌មាន ដោយសារគ្មានឱកាស គ្មានពេលទំនេរ ។

២- សាក្សីទី២ គឺលោក **កង ខេម** :

- កង ខេម ជាជីវពលឃុំដំបូកខ្ពស់ ស្រុកកំណើតគាត់នៅ ភូមិខ្ទុង ឃុំដំបូករូង ពីគ្រប់ជំនាន់ ជំនាន់ប៉ុលពត កងឈានមុខកងស្រួច គាត់អ្នកជីកសាកសពរកមាសឆ្នាំ១៩៧៩ ហើយបានដឹង និងឃើញនាង រស់ សេរីសុទ្ធា អ្នកចម្រៀងដ៏ល្បីត្រូវបានយកមកសម្លាប់នៅទំនប់គោកព្រីងក្នុងភូមិខ្ទុង ពួកវាអោយគាត់ច្រៀងពេលសំរាកបាយរួចកន្លះៗម៉ោងដាក់មេក្រូរាល់ថ្ងៃក្រោយមកក៏យកទៅសម្លាប់ ។

ក្រោយពីបានពិចារណាទៅលើទីតាំងទាំង ៦ រួចហើយ យើងសំរេចចិត្តចុះទៅទីតាំង (តុងឡុង ឬព្រៃប្រម៉ង់ពង) ។ ទីតាំងនោះឆ្ងាយពីសាលាឃុំ ៥គីឡូម៉ែត្រ ។ យើងបានធ្វើដំណើរមានគ្នាចំនួន៧នាក់ក្នុងនោះមានក្រុមស្រាវជ្រាវ ៣នាក់, កង ខេម ជាកងជីវពលឃុំ, សៀង សារ៉េត ជានគរបាល, ឃឹម វ៉ាង ជា នគរបាល, ញ៉ាញ់ វិន ជាប្រជាជន ។

ប្រជាជន និងកងជីវពលទាំងនេះសុទ្ធតែជាអ្នកស្គាល់ទីតាំង និងស្គាល់រណ្តៅសំលាប់ ។ យើងធ្វើដំណើរទៅដល់ភូមិខ្ទុងដោយរថយន្តទៅមុខមិនរួច ។ ម៉ោង១រសៀលយើងទាំង៧នាក់បានធ្វើដំណើរចំងាយ៤គីឡូម៉ែត្រទៅ និងមក៨គីឡូម៉ែត្រ ។ ផ្លូវដែលយើងដើរ គឺផ្លូវរទេះ ហើយតាមសងខាងផ្លូវមានសុទ្ធតែព្រៃ មានតែផ្លូវដើរទេ បើសិនគ្មានប៉ូលិស យើងឋិតក្នុងការផ្សងព្រេងដ៏

គ្រោះថ្នាក់ ។ នៅម៉ោង១១:៣០នាទីទៅដល់ទីតាំងគុកឡូង(ព្រៃប្រម៉ង់ពង) ហើយយើងបានឃើញរណ្តៅបេដែលជាទីតាំងសំលាប់មួយកន្លែងទំហំ១០ម៉ែត្រ ជំរៅ២ម៉ែត្រ លប់ខ្លះហើយ ។ សាក្សីបានដឹងថាទីនេះមានរណ្តៅបេច្រើន ហើយទីតាំងសំលាប់ពី៣-៤នាក់ពេញព្រៃគុកឡូងតែម្តង រលប់អស់ ជួនវាយចោលមិនកប់ផង ។ អ្នកស្លាប់នៅក្នុងរណ្តៅបេ៥២នេះប្រហែលពី៥០នាក់ទៅ៦០នាក់ក្នុង១រណ្តៅ ហើយមានប្រហែល៦ទៅ១០រណ្តៅ សរុបចំនួនអ្នកស្លាប់ក្នុងរណ្តៅបេ៥២មានពី៥០០០ទៅ៦០០០នាក់ ។ ឯក្នុងព្រៃរាប់មិនអស់ទេ ។

ចំពោះពត៌មាននៃការចុះស្រាវជ្រាវកាលពីលើកទី២នៅស្រុកឱរ៉ាល់មានដូចតទៅៈ

- **ប្រវត្តិស្រុកឱរ៉ាល់**

ស្រុកឱរ៉ាល់ សម័យលន់ណុលគ្មានទេ គឺពួកខ្មែរក្រហមគ្រប់គ្រងទាំងស្រុងគិតចាប់ពីក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧០ ទល់ឆ្នាំ១៩៧៥ ហើយក្រោយរំដោះ១៩៧៩មកដល់ឆ្នាំ១៩៨៥ ក៏ខ្មែរក្រហមនៅតែគ្រប់គ្រងដដែល ។ ប៉ុន្តែនៅឆ្នាំ១៩៨៥ទើបរបបអតីតៈរដ្ឋកម្ពុជាបានតែ៤ឆ្នាំទេ ។ លុះឆ្នាំ១៩៨៩ ពួកខ្មែរក្រហមវាយយកបានម្តងទៀតរហូតឆ្នាំ១៩៩៥ ។ ចាប់ពីឆ្នាំ១៩៩៥ទើបបានកើតសាលាស្រុកឱរ៉ាល់បានឡើងវិញ ។ ដូច្នេះស្រុកនេះមិនស្ថេរភាពទេ ទីតាំងសាលាស្រុកសំណង់ទីកន្លែងធ្វើការមិនសមរម្យមន្ត្រីធម្មការស្រុក វប្បធម៌ស្រុកមិនទាន់រៀបរយបានល្អទេ បញ្ហាឯកសារគ្មានអភិបាលរងក៏ក្តាប់មិនបានឡើយ ។

- **លក្ខណៈភូមិសាស្ត្រស្រុក**

អំពីពត៌មានទូទៅក្នុងស្រុកឱរ៉ាល់ឋិតនៅទិសពាយ័ព្យ ខេត្តកំពង់ស្ពឺ ចំងាយ៥៨គីឡូម៉ែត្រ ឋិតនៅខាងឆ្វេងដៃជាប់ផ្លូវលេខ៤២ ។ ស្រុកឱរ៉ាល់សំបូរទៅដោយភ្នំធំៗ ព្រៃស្រោងដុះពាសពេញដីស្រែតិចតួចណាស់ ។ ជាស្រុកសំបូរជំងឺគ្រុនចាញ់ចាប់ពីខែ១០តទៅ ។ ស្រុកនេះមានព្រំប្រទល់ ខាងជើងទល់នឹងស្រុកភ្នំក្រវ៉ាញ ខេត្តពោធិសាត់ ខាងលិចទល់នឹងស្រុកថ្ពង ខាងកើតទល់នឹងស្រុកសំរោងទង និងខាងត្បូងទល់នឹងភ្នំស្រួច ។

- **ពត៌មានផ្សេងៗ**

បញ្ហាសន្តិសុខ ពួកចោរព្រៃពីមុនមាន ប៉ុន្តែឥឡូវនេះមិនចោទទេ ។ យើងបានធ្វើដំណើរតាមផ្លូវជាតិលេខ៤២ក្រុមដោះមីនកំពុងតែដោះក្បែរផ្លូវជាតិជាប់ចិញ្ចើមថ្នល់រថយន្តមិនអាចបើកខុសពីផ្លូវបានទេ ។

- **ពត៌មានទីតាំងឧក្រិដ្ឋកម្ម**

អភិបាលស្រុកក្តាប់មិនបានសោះទេ ឯមន្ត្រីនានារបស់ស្រុកគ្មាននរណាម្នាក់បានដឹងទេ ព្រោះស្រុកនេះជាស្រុកមួយមិនស្ថិរភាពនៅបានមួយកន្លែងទេ រើផ្លាស់ប្តូរជានិច្ចតំបន់ប្រទាញប្រទង់ណាស់ ហើយខ្លាំងបំផុត ។ ប៉ុន្តែយើងបានដឹងជាមុនតាមរយៈនាយខុទ្ទកាល័យខេត្តប្រាប់ថានៅមន្ទីរ៩៩នៅស្រែមួយរយក្នុងឃុំត្រពាំងជោចំងាយ២០គ.មពីសាលាស្រុកឱរ៉ាល់ ។ ទីតាំងមួយទៀតនៅមន្ទីរ៩៩ដែរឋិតនៅឃុំរស្មីសាមគ្គី ។ ឃុំទាំងពីរនេះទៅឃុំរស្មីសាមគ្គីមិនអាចឆ្លងស្ពឹងបានទេបើទៅតាមភ្នំស្រួចទើបទៅបាន ។

ការធ្វើដំណើរចេញពីសាលាស្រុកឱរ៉ាល់ យើងបានឆ្លងស្ទឹងមួយដោយប្រថុយឆ្លងស្ពានបាក់បែកមួយក៏បានរួចផុត ធ្វើដំណើរតាមផ្លូវរទេះទៅត្រពាំងជោឆ្លងកាត់ព្រៃជិតជិតពុំមានប្រជារាស្ត្ររស់នៅសងខាងផ្លូវឡើយ ម៉ូតូ កង់ មនុស្សធ្វើដំណើរក៏គ្មាន ស្ងាត់ឈឹងតែម្តង ។ ចំងាយផ្លូវដល់ទៅ២០គ.មដោយឆ្លងកាត់តាមស្ទឹងពីរ ផ្លូវនេះមិនត្រឹមតែលំបាកទេ គឺមហាលំបាកដោយសារផ្លូវលិចទឹកខូងជ្រៅៗ ទួលកណ្តាលកល់ទ្រូងរថយន្ត ជួនផុងលិចទឹកដល់តួឡានក៏មាន រអិល ដូច្នេះធ្វើដំណើរបានប្រហែល១០គ.ម ដល់ព្រៃតាដុកទៅមុខលែងរួច ព្រោះផ្លូវល្បប់ផុងជ្រៅកល់ទ្រូងឡានទៅមិនរួច ។

**សេចក្តីសន្និដ្ឋាន**

ក្នុងដំណើរចុះទៅកាន់ខេត្តកំពង់ស្ពឺលើកទី៣នេះ ទៅកាន់ស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់យើងមិនបានទទួលលទ្ធផលអ្វីឡើយ ព្រោះយើងជួបនូវឧបសគ្គមួយចំនួនដូចជា ខ្វះសុវត្ថិភាព និងសន្តិសុខមិនទាន់ធានាបាន១០០ភាគរនៅឡើយទេដែលតំរូវឲ្យមានការចូលរួមសហការណ៍ពីរដ្ឋអំណាចមូលដ្ឋានទើបធ្វើឲ្យការចុះស្រាវជ្រាវយើងអាចដំណើរការទៅបានស្រួល ។ ម៉្យាងទៀតបញ្ហាផ្លូវជាឧបសគ្គមួយធ្ងន់ធ្ងរជាងគេបំផុត ព្រោះស្ថានភាពផ្លូវគមនាគមន៍គិតមកដល់ពេលនេះមិនមិនខុសប្លែកពីកាលដែលយើងចុះទៅធ្វើការស្រាវដូចលើកមុនៗប៉ុន្មានឡើយ ទោះជាមានកំពុងមានការជួសជុលបាកខ្លះៗក្តី ជាពិសេសគឺស្រុកឱរ៉ាល់ ។

ថ្វីត្បិតតែបញ្ហាមីនត្រូវបានបោសសំអាតតាមដងផ្លូវអស់ភាគច្រើនក្តី ប៉ុន្តែក៏នៅតែទាមទារឲ្យមានការចូលរួមសហការណ៍ពីរដ្ឋអំណាចដែរ ដើម្បីជៀសវាងការចុះទៅស្រាវជ្រាវដោយប្រថុយគ្រោះថ្នាក់ ព្រោះមានតែអ្នកមូលដ្ឋានទេដែលអាចប្រាប់យើថាកន្លែងណាដែលមីនត្រូវបានបោសសំអាតរួច និងកន្លែងណាដែលមិនត្រូវបានបោសសំ អាតដោយអន្តការជាដ ។

ចំពោះស្រុកភ្នំស្រួចនៅទីតាំងដែលយើងមិនទាន់ចុះទៅដល់ បញ្ហាផ្លូវក៏ចោលជាឧបសគ្គដែរ ពោកគឺយើងមិនអាចធ្វើដំណើរទៅដល់ទីតាំងស្រាវជ្រាវដោយរថយន្តបានទេ ព្រោះផ្លូវកាត់តាមព្រៃតូចចង្អៀតមានចំងាយជាង១០គីឡូម៉ែត្រអាចធ្វើដំណើដោយថ្មើជើង ឬរទេះគោប៉ុណ្ណោះ ។

ដូច្នេះដំណោះស្រាយទៅថ្ងៃមុខក្នុងការចុះស្រាវជ្រាវលើកក្រោយៗទៀតទាមទារឲ្យមានការកំណត់ពេលចុះទៅនៅខែប្រាំងក្នុងរយៈពេលយ៉ាងតិច២ថ្ងៃ ព្រោះស្ថានភាពផ្លូវពុំល្អ មានទីតាំងឆ្ងាយៗពីគ្នា និងមិនចំថ្ងៃដែលមន្ត្រីរាជការត្រូវឈប់សម្រាកដើម្បីបានការជួយសហការណ៍ល្អពីមូលដ្ឋាន ដើម្បីសន្តិសុខ និងសុវត្ថិភាព ។